# វុធ លីណូ_សាលាសំណាក់
# VUTH LYNO_SALA SAMNAK

ពិព័រណ៍ | EXHIBITION: November 21, 2020 – March 1, 2021
សម្ពោធ | OPENING NIGHT: Friday November 20, 2020, 6:00 pm
ជួបជាមួយសិល្បករ | ARTIST TALK: Saturday February 13, 2021, 4:00 pm
MIRAGE Contemporary Art Space Siem Reap

MIRAGE Contemporary Art Space art@mirage-collective.com

# សាលាសំណាក់

ពិព័រណ៍ សាលាសំណាក់ បង្ហាញជូននូវស្នាដៃថ្មីៗរបស់សិល្បករ វុធ លីណូ ក្នុងនោះមានស្នាដៃបង្កំទំហំធំមួយធ្វើពីពន្លឺ និងរូបគំនូរមួយចំនួនទៀត ដែលចូលរួមបង្កើតដោយ គង់ ស៊ីដែន, ព្រហ្ម អ៊ីរ៉ូ និង ថន សុខ។ នៅក្នុងពិព័រណ៍នេះ សិល្បកររូបនេះចង់ពិនិត្យលើទីសហគមន៍មួយប្រភេទដែលមាននៅពាសពេញប្រទេសកម្ពុជាគឺ សាលាសំណាក់។ សាលាសំណាក់ គឺជាផ្នែកមួយនៃប្រពៃណីនិងជីវភាពរស់នៅប្រចាំថ្ងៃនៅកម្ពុជា ហើយវាជានិមិត្តរូបនៃជីវិតជនបទខ្មែរ។ ជាទូទៅ វាជាសំណង់សាមញ្ញមួយបែប ដែលគេតែងសង់នៅតាមមាត់ផ្លូវឬនៅក្នុងភូមិ សម្រាប់ឲ្យអ្នកដំណើរឆ្លងកាត់ ចូលសម្រាកអាស្រ័យមួយពេលៗ។ ក្នុងករណីខ្លះ អ្នកភូមិរៀបធ្វើពិធីផ្សេងៗនៅក្នុងសាលាសំណាក់។

ទំនៀមទម្លាប់បែបនេះ គឺមានប្រវត្តិយ៉ាងហោចណាស់តាំងពីមុនសម័យអង្គរមកម្លេះ។ ឈ្មោះបុរាណរបស់វាគឺ «អគ្និគ្រិហ» មានន័យថាផ្ទះអគ្គិ ដែលទំនងសំដៅលើការគោរពបូជាអាទិទេពនៅក្នុងសាលានេះ។ ប៉ុន្តែសព្វថ្ងៃនេះ មានសាលាសំណាក់មួយចំនួន ត្រូវបានគេបោះបង់មិនអើពើ ទុកឲ្យទ្រុឌទ្រោមខូចខាតក៏មាន។ តួនាទីដើមសំខាន់របស់វា ដែលជាទីសម្រាប់អ្នកដំណើរ ឬភ្ញៀវចូលសម្រាកមួយពេលៗនេះ ត្រូវបានជំនួសដោយហាងកាហ្វេទំនើបៗ និងភោជនីយដ្ឋានតាមដងផ្លូវវិញ ។

នៅក្នុងពិព័រណ៍ សាលាសំណាក់ លីណូ មានចំណាប់អារម្មណ៍ជាខ្លាំងទៅលើតួនាទីរបស់សាលានេះ ក្នុងការបម្រើផលប្រយោជន៍ទាំងបែបវប្បធម៌និងសង្គម និងការវិវត្តន៍នៃតួនាទីសហគមន៍របស់វា។ ម៉្យាង អ្នកភូមិអ្នកស្រុកប្រាស្រ័យទាក់ទងនិងបង្កើតទំនាក់ទំនងសហគមន៍តាមរយៈការរៀបចំពិធីផ្សេងៗនៅក្នុងសាលាសំណាក់។ ជាងនេះទៅទៀត អ្នកធ្វើដំណើរឬអ្នកមិនដែលស្គាល់គ្នាជិតឆ្ងាយ អាចជួបនិងប្រាស្រ័យទាក់ទងគ្នា នាទីសំចតនេះ។ ទំនាក់ទំនងសង្គម និងឱកាសជួបចែជន្យទាំងនេះ គឺកើតមានឡើងនៅក្នុងសាលាសំណាក់ ដែលភាគច្រើនត្រូវបានចូលរួមកសាងឡើង ដោយអ្នកភូមិអ្នកស្រុក។

ពិព័រណ៍ សាលាសំណាក់ បង្ហាញពីស្ថានភាពក៏ដូចជាតួនាទីសង្គមមិនថិតថេរនៃអគារទាំងនេះ។ ស្នាដៃបង្កំធ្វើពីអំពូលនីអុង ដែលព្យួរក្នុងលំហវិចិត្រសាល មើលទៅហាក់ដូចជាមិនមែននៅក្នុងពិភពពិត និងឆ្លុះបញ្ចាំងពីការចង់រក្សាបាននូវប្រពៃណីខ្មែរមួយនេះ ដោយកំពុងប្រឈមនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម។ ភាពដូចក្នុងសុបិន ដែលកើតឡើងដោយសាររស្មីពន្លឺពណ៌ខៀវនេះ បង្កើតបានជាបទពិសោធន៍ដ៏ពិសេសមួយនៅពេលងងឹត។ ភាពពាក់កណ្តាលរូបធាតុ និងភាព

# សាលាសំណាក់

ផុយស្រួយនៃគ្រោងអគារនេះ ចង្អុលដល់ស្ថានភាពមិនប្រាកដប្រជានៃតម្រូវការ និងការបាត់បង់ជាអន្លើនៃសាលាសំណាក់សព្វថ្ងៃ។

បើគ្មានវត្តមានរបស់ទស្សនិកជនទេ សាលាសំណាក់នេះនឹងបាត់បង់អត្ថន័យនិងគោលបំណងរបស់វា ហើយក្លាយជាទីទទេ ។ រាល់ការចូលទស្សនាម្តងៗ នឹងមានភាពខុសប្លែកគ្នា ហើយគឺបទពិសោធន៍ដោយឡែកៗរបស់ទស្សនិកជននេះហើយ ដែលផ្តល់អត្ថន័យដល់វា។ ដូច្នេះហើយ ផ្ទាំងគំនូរនៃសាលាសំណាក់មានបំភ្លឺពន្លឺចែងចាំងចំនួន ៦ ផ្ទាំង ដែលដំបូងតំណាងដោយផ្ទាំងខ្មៅទទេ នឹងបង្ហាញខ្លួនម្តងមួយៗ នៅក្នុងអំឡុងពេលនៃពិព័រណ៍នេះ ឆ្លុះបញ្ចាំងពីតម្លាភាពនិងភាពប្រែប្រួលនៃសាលាសំខាន់នេះ។

សេចក្តីថ្លែងអំណរគុណ
គំនូសឌីជីថល៖ គង់ ស៊ីដែន
ផលិតកម្ម និងដំឡើង៖ ព្រហ្ម អ៊ីរ៉ូ
គំនូរ៖ ថន សុខ

សូមបង្ហាញយោបល់របស់អ្នកក្នុងសៀវភៅមួយនេះ ឬក៏ក្នុងបណ្តាញសង្គមជាមួយ #SalaSamnak។

# SALA SAMNAK

“Sala Samnak” introduces new works of light installation and paintings by Vuth Lyno created with Kong Siden, Prum Ero and Than Sok. It explores a traditional communal space that exists throughout Cambodia: sala samnak, a rest hall. Sala samnak is part of the fabric of the daily life of Cambodia, and its presence is symbolic of the Cambodian countryside. They are usually modest structures built on the roadside or in the village for passersby and visitors. In some cases, villagers use it for communal ceremonies or events.

This practice dates back at least to before the Angkorian period. The ancient name of this structure, ‘agni gRha’, translates into house of fire, and possibly refers to the rituals to the divine which took place in it. Today however, many sala samnak structures become neglected and abandoned. Their primordial function, that of offering a rest place for the passersby and travelers, is replaced by modern cafes and restaurants built along the roadside.

In “Sala Samnak” Lyno is interested in the cultural and social functions of the rest hall and the evolution of its communal function. In one such use, villagers interact and create communal relations through rituals, which take place in the structure. On the other hand, visitors, and strangers may meet and rest together as they commute along their respective journeys. These social relations and chances of an encounter are made possible under sala samnak, which is usually generously built by the villagers.

“Sala Samnak” illustrates the precarious state of these structures and their social, ungraspable aspects. The neon-light installation suspended in the gallery space is otherworldly and reflects a country grasping onto its traditions whilst experiencing rapid economic and social development. This dream-like quality, produced by the radiating blue light, creates an unearthly experience that only appears after dark, hinting at the semi-immateriality and fragility of the structure and the uneven relevance of sala samnak today.

# SALA SAMNAK

Without the visitors, the sala samnak loses its purpose and simply becomes an empty space. Every visit to the space is different and it is shaped by the individual encounters of passersby who will give it its ultimate meaning. Therefore, over the duration of the exhibition at MIRAGE, six paintings of glowing rest halls, represented by six black voids, will be appearing one by one. This ensures that the transient nature and changing character of these ‘rest halls’ will be reflected.

Acknowledgement:
Digital rendering: Kong Siden
Production and installation: Prum Ero
Painting: Than Sok

We invite you to become the part of “Sala Samnak”:
Share your experiences and thoughts online with the hashtag #SalaSamnak.

# វុធ លីណូ

វុធ លីណូ (កើតឆ្នាំ ១៩៨២ នៅ ភ្នំពេញ) ជាសិល្បករ អ្នករៀបំពិព័រណ៌ និងនាយកសហស្ថាបនិករបស់គម្រោងសិល្បៈស-ស។ ការងារសិល្បៈរបស់គាត់ភាគច្រើនតែងមានលក្ខណៈចូលរួម ពិនិត្យលើការរៀនសូត្ររួមគ្នាដកពិសោធន៍ និងចែករំលែកនូវមតិសំឡេងនានាតាមរយៈការផ្លាស់ប្តូរគ្នា។ គាត់ច្រើនអញ្ជើញអ្នកចូលរួមគម្រោងអោយរួមគ្នាបង្កើតអត្ថន័យនៃស្នាដៃសិល្បៈរបស់គាត់។ គាត់ចាប់អារម្មណ៍លើមីក្រូប្រវត្តិសាស្ត្រទស្សនៈអំពីសហគមន៍ការបង្កើតទីកន្លែងនិងស្ថានភាពសង្គមផ្សេងៗ។ ក្នុងនាមជាសិល្បករ គាត់បង្កើតស្នាដៃសិល្បៈតាមរយៈចម្លាក់ រូបថត សំឡេង ពន្លឺ និង វីដេអូ ហើយភាគច្រើនបង្ហាញក្នុងទម្រង់ស្នាដៃបង្កំ។ គាត់ចាប់អារម្មណជាពិសេសលើសាច់រឿងរបស់មនុស្ស សម្ភារៈ និងរបៀបដែលទស្សនិកជនទស្សនានិងមានប្រតិកម្មជាមួយវា។

លីណូ បានបង្ហាញស្នាដៃសិល្បៈរបស់លោកទាំងក្នុងប្រទេសកម្ពុជា ក្នុងតំបន់អាស៊ីអាគ្នេយ៍ និងនៅលើឆាកអន្តរជាតិ រួមមានពិព័រណ៌និងមហោស្រពសំខាន់ៗជាច្រើនដូចជា Asia Pacific Triennial, Biennale of Sydney, Singapore International Festival of Arts, និង Gwangju Biennale។ ស្នាដៃសិល្បៈរបស់គាត់បានតាំងបង្ហាញនៅតាមវិចិត្រសាលនិងសារមន្ទីរធំៗនានាដូចជា Museum of Contemporary Art Taipei; Gallery of Modern Art, Brisbane; Metropolitan Museum of Manila; the Art Gallery of New South Wales, Sydney; the National Gallery of Indonesia, Jakarta; Centre for Contemporary Art Ujazdowski Castle, Warsaw; Guangdong Times Museum, Guangzhou; Osage Gallery, Hong Kong; និង Chiang Mai City Arts & Cultural Centre ។

លីណូ បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកប្រវត្តិសាស្ត្រសិល្បៈពីសាកលវិទ្យាល័យ State University of New York, Binghamton, New York ដោយមានការគាំទ្រពីអាហារូបករណ៍ Fulbright Fellowship (២០១៣-២០១៥) និងអនុបណ្ឌិតផ្នែកអភិវឌ្ឍន៍អន្តរជាតិពី RMIT University, Melbourne ដោយមានការគាំទ្រពីអាហារូបករណ៍ Australian Endeavour Award (២០០៨-២០០៩)។

# VUTH LYNO

Vuth Lyno (born 1982, Phnom Penh) is an artist, curator and co-founding artistic director of Sa Sa Art Projects, a Phnom Penh's artist-run space initiated by Stiev Selapak collective. His artistic and curatorial practices are participatory in nature, exploring communal learning, experimentation, and sharing of multiple voices through exchanges. He usually involves project's participants in the production of meaning of the artwork. His interest intersects micro histories, notions of community, place making, and production of social situations.
As an artist, Lyno works with various media including sculpture, photography, sound, light, and video, often resulting in an installation. He is particularly interested in the agency of human stories, materiality, and how the audience engages with them.

Lyno has presented his artworks widely in Cambodia, regionally and internationally including at major exhibitions and festivals such as Asia Pacific Triennial, Biennale of Sydney, Singapore International Festival of Arts, and Gwangju Biennale. His artworks have appeared at institutions such as Museum of Contemporary Art Taipei; Gallery of Modern Art, Brisbane; Metropolitan Museum of Manila; the Art Gallery of New South Wales, Sydney; the National Gallery of Indonesia, Jakarta; Centre for Contemporary Art Ujazdowski Castle, Warsaw; Guangdong Times Museum, Guangzhou; Osage Gallery, Hong Kong; and Chiang Mai City Arts & Cultural Centre.

Lyno holds a Master of Art History from the State University of New York, Binghamton, New York, supported by a Fulbright Fellowship (2013 – 2015), and a Master of International Development from RMIT University, Melbourne supported by the Australian Endeavour Award (2008 – 2009).

# កិច្ចសម្ភាសន៍

**_ តើអ្វីទៅជា «សាលាសំណាក់»?**

សាលាសំណាក់ គឺជាសំណង់ម្យ៉ាងដែលភាគច្រើនសាងសង់ដោយអ្នកភូមិនៅតាមតាមដងផ្លូវ ឬនៅក្នុងភូមិស្រុកសម្រាប់ឲ្យអ្នកដំណើរជិតឆ្ងាយអាចចូលឈប់សម្រាកមួយពេលៗ។ ទំនៀមទម្លាប់នេះមានប្រវត្តិយ៉ាងហោចណាស់តាំងពីមុនសម័យអង្គរមកម្ល៉េះ។ យើងឃើញមានសាលាសំណាក់ធ្វើពីថ្មបន្សល់ទុកពីសម័យអង្គរជាដើម។ តែនាពេលបច្ចុប្បន្នសំណង់ នេះមានការផ្លាស់ប្តូរទម្រង់ទៅជាឈើ ឬបេតុងជាដើម។ វាជាផ្នែកមួយនៃប្រពៃណី និងជីវភាពរស់នៅប្រចាំថ្ងៃក្នុងសង្គមខ្មែរ។ ខ្ញុំមានចំណាប់អារម្មណ៍ទៅលើទស្សនៈក្នុងការកសាងសំណង់សម្រាប់សាធារណជនសម្រាប់សហគមន៍ និងក្នុងករណីនេះគឺសម្រាប់អ្នកមកពីទីទៃមិនដែលស្គាល់គ្នា ឲ្យបានចូលសំចតជាបណ្តោះអាសន្នក្នុងដំណើរជិតឆ្ងាយរបស់គេ។

**_ តើយើងអាចស្វែងរកសំណង់បែបនេះនៅទីណាបានក្នុងប្រទេសកម្ពុជាយើង?**

វាមានស្ថានភាព និងលក្ខណៈខុសៗគ្នានៅទូទាំងប្រទេស ប៉ុន្តែសព្វថ្ងៃគេឃើញច្រើនមានសាលាសំណាក់នៅតាមទីជនបទ។ ចំណែកនៅក្នុងទីក្រុងវិញ គេមិនសូវឃើញមានសំណង់អគារសម្រាប់សាធារណជនបែបនេះទេ ហើយវាថ្លៃក្នុងការសាងសង់។ នៅតាមកន្លែងខ្លះ សាលាសំណាក់ត្រូវបានគេបោះបង់ចោលមិនអើពើរហូតដល់ទ្រុឌទ្រោមក៏មានហើយនៅកន្លែងខ្លះគេនៅតែបន្តប្រើប្រាស់វា។ ដូច្នេះវាមានស្ថានភាពចម្រុះនៅទូទាំងប្រទេសកម្ពុជា។

**_ តើបច្ចុប្បន្ននេះគេប្រើប្រាស់សាលាសំណាក់ដើម្បីអ្វី?**

គោលបំណងរបស់សាលាសំណាក់ គឺសម្រាប់ឲ្យមនុស្សទូទៅឈប់សម្រាប់មួយពេលៗមុននឹងពួកគេបន្តដំណើរទៅមុខទៀត។ វាជាប្រពៃណីដ៏ចំណាស់មួយ។ ទោះជាយ៉ាងណាក៏ដោយនៅពេលសង្គមកាន់តែទំនើប ហើយប្រពៃណីបានវិវត្តិប្រជាជនឥឡូវចូលចិត្តសម្រាកនៅក្នុងភោជនីយដ្ឋាន ឬហាងកាហ្វេជំនួសវិញ។ ប៉ុន្តែតួនាទីមួយទៀតនៃសាលាសំណាក់គឺផ្តល់ជាទីកន្លែងសម្រាប់ប្រារព្ធពិធីនានាដូចជាពិធីបុណ្យតាមព្រះពុទ្ធសាសនា ឬពិធីចម្រើនព្រះជន្មអ្នកសំខាន់ៗ ឬចាស់ព្រឹទ្ធាចារ្យក្នុងភូមិជាដើម។ ទាំងអស់នេះសុទ្ធសឹងជាព្រឹត្តិការណ៍ដែលសហគមន៍រៀបចំឡើងដោយខ្លួនឯង។ វាជាកន្លែងសហគមន៍មួយដែលមនុស្សទូទៅនរណាជានរណាក៏អាចប្រើប្រាស់បាន។

**_ ការងាររបស់លោកតែងតែផ្តោតទៅលើការសិក្សាពីទីកន្លែងសហគមន៍ដូចជា អគារស ( ប៊ូឌីងស ) នៅភ្នំពេញជាដើម។ ហើយក្នុងនាមលោកជាអ្នករៀបចំកម្មវិធីសិល្បៈ លោកនិយាយថាចង់ឲ្យសិល្បៈមានការរីកសាយភាពដល់សាធារណជនលើសពីក្នុងសាលពិព័រណ៍។ លោកតែងប្រើប្រាស់ទស្សនៈអំពីលំហ ក៏ដូចជាមុខងារនៃវត្ថុនិងទីសហគមន៍។ ចុះនៅក្នុងពិព័រណ៍នេះ ហេតុអ្វីបានជាលោកចង់បង្ហាញអំពីសាលាសំណាក់ដែលជាទីកន្លែងសម្រាប់សហគមន៍ នៅក្នុងវិចិត្រសាលទៅវិញ?**

ការងាររបស់ខ្ញុំភាគច្រើនរួមបញ្ចូលកត្តាពីរ។ មួយគឺខ្ញុំចង់បង្ហាញដល់និងមានទំនាក់ទំនងជាមួយសាធារណជនឲ្យបានកាន់តែច្រើនដោយរៀបចំកម្មវិធីនៅទីធ្លាសហគមន៍ ឬទីសាធារណៈ។ ហើយមួយទៀតនោះគឺ ស្នាដៃសិល្បៈភាគច្រើនរបស់ខ្ញុំគឺតែងតែដាក់តាំងបង្ហាញនៅក្នុងវិចិត្រសាល បើទោះបីជាស្នាដៃទាំងនោះមានទំនោរទាក់ទងនឹងប្រធានបទសហគមន៍ក្តី ឬក៏មានការចូលរួមពីសំណាក់អ្នកចូលរួមគម្រោងក្តី។ ជាក់ស្តែងសម្រាប់ស្នាដៃ "សាលាសំណាក់ " មួយនេះ ខ្ញុំមានចំណាប់អារម្មណ៍លើគំនិតនៃការបង្កើតទីធ្លាសម្រាក ឬប្រើប្រាស់រួមសម្រាប់សាធារណជន ភ្ញៀវមកពីទីជិតឆ្ងាយឆ្លងកាត់ ក៏ដូចជាសម្រាប់អ្នកភូមិស្រុកផងដែរ។

នៅវិចិត្រសាល មីរ៉ាស្ស មានជ្រុងមួយដែលមានបង្អួចកញ្ចក់សងខាង ហើយគេអាចមើលឃើញយ៉ាងច្បាស់ពីផ្លូវថ្នល់មក។ ខ្ញុំបានគិតពីវិធីសាស្ត្រធ្វើយ៉ាងម៉េចឲ្យគេអាចមើលឃើញស្នាដៃរបស់ខ្ញុំកាន់តែច្រើន។ ស្នាដៃរបស់ខ្ញុំ គឺជាបង្គុំគ្រោង

# កិច្ចសម្ភាសន៍

ឆ្អឹងនៃអគារធ្វើពីអំពូលនីអុងជាទម្រង់សាលាសំណាក់។ ខ្ញុំសម្រេចដាក់ស្នាដៃនេះនៅក្នុងជ្រុងខាងមុខនៃវិចិត្រសាល ហើយបែរមុខទៅរកផ្លូវ។ ធ្វើបែបនេះ អ្នកទស្សនាអាចមើលឃើញវាបានទាំងសងខាង ដោយគេអាចដើរមើលពីខាងក្នុងវិចិត្រសាលក៏បាន និងដើរមើលពីខាងក្រៅវិចិត្រសាលក៏បាន គឺឃើញស្នាដៃនេះម្ខាងម្តង ឬ ១៨០ ដឺក្រេម្តង។ ខ្ញុំចូលចិត្តពីរបៀបនៃការប្រើប្រាស់លំហទាំងក្នុង និងក្រៅនៃវិចិត្រសាល ដើម្បីបង្កើននូវបទពិសោធន៍ទស្សនាដល់ទស្សនិកជន។

**_ ពិតណាស់ពិព័រណ៌ "សាលាសំណាក់ "គឺពិចារណាអំពីគំនិតនៃភាពអាចប្រើប្រាស់បាន។ តែស្នាដៃនេះ តំណាងឲ្យភាពផ្ទុយគ្នាទៅវិញនៃសំណង់ដែលគេឃើញមាននៅច្រើនទីកន្លែង និងងាយប្រើប្រាស់បាន ដោយសារវាធ្វើពីសម្ភារផុយស្រួយ ហើយគេមិនអាចចូលប្រើប្រាស់វាបានទេ ព្រោះវាត្រូវបានព្យួរក្នុងលំហ ។**

គំនិតដំបូងរបស់ខ្ញុំគឺបង្កើតវាក្នុងទំហំប៉ុនសាលាសំណាក់ជាក់ស្តែង ឬយ៉ាងហោចជិតប៉ុនទំហំជាក់ស្តែង ហើយឲ្យទស្សនិកជនអាចដើរចូលបាន។ ប៉ុន្តែខ្ញុំធ្វើដូច្នេះមិនបានដោយសារទំហំកំណត់របស់វិចិត្រសាល។ ដូច្នេះហើយខ្ញុំក៏បានកែសម្រួលដោយបង្រួមមាត្រដ្ឋានវា និងរកយុទ្ធសាស្ត្រធ្វើយ៉ាងម៉េចដើម្បីកុំឲ្យបាត់បង់នូវវិសាលភាពរបស់វា។

អ្នកក៏បាននិយាយអំពីភាពប្រឈមគ្នានៃភាពងាយប្រើប្រាស់នៃសាលាសំណាក់ជាមួយនឹងភាពមិនអាចចូលប្រើប្រាស់បានរបស់ស្នាដៃនេះ។ ពិតណាស់វិចិត្រសាលផ្តល់ឲ្យខ្ញុំនូវលក្ខខណ្ឌ និងកំហិតជាក់ស្តែងនៃលំហ។ ដូច្នេះខ្ញុំត្រូវគិតរិះរកវិធីសាស្ត្រយ៉ាងណាដើម្បីដោះស្រាយបញ្ហានេះ។ ជាចុងក្រោយខ្ញុំបានសម្រេចចិត្តដំឡើងវានៅពាក់កណ្តាលលំហ ដូច្នេះវាមើលទៅហាក់បីដូចជាវាកំពុងអណ្តែត ហាក់បីដូចជាមិនមែនការពិត ជាពិសេសនៅយើងសម្លឹងពន្លឺខៀវដ៏ចញ្ចាចចញ្ចែងរបស់វា។ ខ្ញុំចូលចិត្តគុណភាពនៃពន្លឺបែបហ្នឹង។

**_ តើមានអ្វីពិសេសសម្រាប់អ្នកក្នុងការបង្កើតស្នាដៃជាមួយនឹងពន្លឺ ហើយហេតុអ្វីបានជាអ្នកជ្រើសរើសប្រើវាដើម្បីបង្កើតស្នាដៃបង្គុំមួយនេះ? តើដំណើរការនៃការបង្កើតវាមានលក្ខណៈយ៉ាងណាដែរ?**

ខ្ញុំធ្លាប់ធ្វើការជាមួយនឹងពន្លឺពីមុនហើយ។ ខ្ញុំធ្លាប់បានប្រើប្រាស់ពន្លឺជាសម្ភារនៅក្នុងស្នាដៃខ្ញុំ ប៉ុន្តែនេះគឺជាលើកដំបូងហើយដែលខ្ញុំធ្វើការជាមួយនឹងពន្លឺនីអុងដែលវាជាឧបករណ៍ដ៏ពិបាកធ្វើការជាមួយ និងផុយស្រួយងាយខូចខាតណាស់។ ខ្ញុំបានរៀនសូត្រច្រើនណាស់នៅក្នុងដំណើរការបង្កើតស្នាដៃមួយនេះឡើង។ ខ្ញុំពិតជាមានសេចក្តីរីករាយមែនទែនដែលមានក្រុមការងារ ២ នាក់ទៀតចូលរួមជាមួយខ្ញុំ ដើម្បីជួយគូសគំនូសព្រាង ឌីជីថល និងផលិតកម្ម ក៏ដូចជាដំណោះស្រាយបច្ចេកទេសនៃការដំឡើង។ វាពិតជាមានការលំបាកខ្លាំងបន្តិចដោយសារតែនេះជាសម្ភារថ្មីសម្រាប់ខ្ញុំ។

ខ្ញុំពិតជាចាប់អារម្មណ៍ទៅលើគុណភាពនៃពន្លឺនេះណាស់។ នៅពេលដែលគ្មានអគ្គិសនី វាគ្រាន់តែជាបំពង់កែវពណ៌សប៉ុណ្ណោះគ្មានអ្វីអស្ចារ្យទេ។ តែនៅពេលមានអគ្គិសនី អំពូលនីអុងនេះបញ្ចេញពន្លឺរស្មីចែងចាំង ហាក់ដូចជាមានវេទមន្តពិសេសម៉្យាង។ ខ្ញុំចូលចិត្តវា ហើយខ្ញុំចូលចិត្តអារម្មណ៍នៅពេលឃើញពន្លឺបែបនេះ វាហាក់ដូចពិតជាសណ្តំចិត្តយើង។ ភាពជាវេទមន្ត និងភាពសណ្តំនេះធ្វើឲ្យខ្ញុំគិតនិងផ្សារភ្ជាប់វាទៅនឹងទម្រង់នៃសាលាសំណាក់ និងស្ថានភាពចម្រុះរបស់សាលាសំណាក់នាពេលបច្ចុប្បន្ននេះ។ ជាក់ស្តែងសាលាសំណាក់នៅកន្លែងខ្លះគេបោះបង់វ នៅកន្លែងខ្លះទៀតក៏គេនៅកំពុងប្រើប្រាស់ ហើយក៏មានសាលាសំណាក់ថ្មីៗទៀតដែលគេកំពុងសាងសង់។

ខ្ញុំចង់ភ្ជាប់លក្ខខណ្ឌមិនប្រាកដប្រជារបស់សាលាសំណាក់នេះទៅនឹងគំនិតមួយដែលនៅពេលទស្សនិកជនឃើញស្នាដៃនេះ វាហាក់ដូចជាមិនមែននៅក្នុងពិភពពិត វាដូចជាក្តីសុបិនដែលរូបភាពទាំងនេះហាក់កើតឡើងនៅក្នុងក្តីស្រមៃតែប៉ុណ្ណោះ។ ហើយដោយសារតែអំពូលពន្លឺ វាមានលក្ខណៈរូបធាតុពាក់កណ្តាល គឺរូបរាងជាបំពង់កែវ ប៉ុន្តែយើងមិនអាច

# កិច្ចសម្ភាសន៍

ប៉ះ និងចាប់ពន្លឺរស្មីរបស់វាបាននោះទេ។ ខ្ញុំចូលចិត្តគុណភាពពិសេសបែបនេះដែលបង្កើតចេញពីរូបភាពរបស់វាខ្លួនឯងដែលវាត្រូវនឹងស្ថានភាពលាយឡំគ្នានៃតម្រូវការបច្ចុប្បន្នរបស់ សាលាសំណាក់។ ខ្ញុំភ្លេចប្រាប់ថា សាលាសំណាក់មានឈ្មោះបុរាណថា “អគ្និគ្រិហ” អគ្និ ជាអគ្គី ឬភ្លើង ហើយគ្រិហ ជាផ្ទះ ដែលប្រែមកថា ផ្ទះអគ្គី។ ទំនងពីសម័យបុរាណមានការគោរពបូជាភ្លើងជូនអាទិទេពនៅក្នុងសាលានោះ។ ទីបំផុត ខ្ញុំចាប់អារម្មណ៍គិតនិងប្រើប្រាស់ឡើងវិញនូវ ពន្លឺ និងភ្លើង ដើម្បីផ្សារភ្ជាប់ទៅនឹងអត្ថន័យដើមរបស់សាលាសំណាក់ដោយច្នៃយកសម្ភារថ្មីនេះ មកបង្កើតបទពិសោធន៍ពិសេសមួយដល់ទស្សនិកជន។

**_ ដូច្នេះ ស្នាដៃសិល្បៈរបស់លោក គឺជាកំណត់ត្រាអំពីការវិវត្តន៍នៃពន្លឺ និងមុខងាររបស់សាលាសំណាក់។ ហើយនាពេលបច្ចុប្បន្ន យើងឃើញមានការវិវត្តន៍នៃលំហផ្សេងៗផងដែរដែលមុខងាររបស់វាបានប្រែប្រួលដោយសារមេរោគរាតត្បាតសកលនេះ។ ទីសាធារណៈ និងទីសហគមន៍នានាប្រែជាមានកំហិត ឬមិនអាចចូលប្រើប្រាស់បាន។ តើលោកយល់ឃើញយ៉ាងណាដែរចំពោះគម្លាតសុវត្ថិភាព និងការផ្លាស់ប្តូរនៃការប្រើប្រាស់របស់ទីលំហទាំងនេះ?**

ជាការពិតណាស់នេះជាការវិវត្តន៍មួយទៀតដែលផ្លាស់ប្តូរបម្រើបម្រាស់ និងការប្រាស្រ័យទាក់ទងនៅទីសាធារណៈ។ បញ្ហានេះលើកជាសំនួរមួយអំពីភាពជិតស្និទ្ធ។ យើងប្រែជាមិនសូវមានភាពជិតស្និទ្ធ មិនសូវស្និទ្ធស្នាលគ្នា ចំណែកទំនងទំនងសង្គមក៏មានកំហិត។ ប៉ុន្តែជាសំណាងរបស់ប្រទេសកម្ពុជាយើងមិនមានការរីករាលដាលធ្ងន់ធ្ងរដូចប្រទេសដទៃទៀតនោះទេ។

ក្នុងនាមជាសិល្បករ ខ្ញុំមានបំណងព្យាយាមសម្របសម្រួលភាពជិតស្និទ្ធហើយខ្ញុំសង្ឃឹមថាតាមរយៈស្នាដៃនេះ និងគុណភាពពន្លឺរបស់វា ខ្ញុំអាចផ្តល់ជាទម្រង់នៃទំនាក់ទំនងថ្មីមួយជាមួយទស្សនិកជនមិនថាអ្នកនៅខាងក្នុងឬ ខាងក្រៅវិចិត្រសាលនោះទេ។ ខ្ញុំសំដៅទៅលើគុណភាពនៃពន្លឺអំពូលនីអុងនេះឯង។ យើងមើលវាឃើញ និងប្រហែលជាអាចចាប់អំពូលបាន តែផ្ទុយទៅវិញយើងមិនអាចចាប់រស្មីពន្លឺបានទេ។ ខ្ញុំសង្ឃឹមថាបទពិសោធន៍បែបនេះអាចអោយយើងនឹកស្រមៃសញ្ជឹងគិតម្តងហើយម្តងទៀត។

# INTERVIEW

**_ What is "Sala Samnak"?**

Sala samnak (Khmer rest hall), is a very particular kind of building that is built most of the time by villagers and is usually by the roadside or sometimes in the villages for visitors or passersby to rest, during the journey passing through.

This tradition dates back a very long time ago to at least prior to the Angkorian period. There is some evidence from the Angkorian period of stone structure and so on. But these days the building has different forms, either wood or concrete and whatnot. They are part of the fabric of the daily life of Cambodia. I am very interested in the idea of building space for the public, for the community and in this case building space for anonymous people, strangers to have a temporary shelter as they pass by.

**_ Where can you find these structures today in Cambodia?**

It has different state and relevance across the country, but it certainly has more currency and usage in the rural settings. In urbanized areas you don't really see much of this idea of building space for the public. And it is very expensive to build. You will definitely see more of those structures in the villages. In some areas, the sala samnak structures are neglected, in others they are still put to use. Therefore, there is a mixed status of sala samnak across Cambodia.

**_ What is the current use of sala samnak?**

The purpose is for people to stop by and rest before they move on their journey or trip. It's quite an old tradition. However, as society modernized, the tradition evolved, people prefer to rest in a restaurant or cafe instead of in a shelter by the road. But there is another function of this structure, such as serving as space for ceremonies, or certain rituals, Buddhist events, and the birthday of an important elder in the village. These are communal events facilitated by the villagers themselves. It is an available communal space, very accessible for everyone.

**_ Your work often refers to and analyses Cambodian communal space, such as the White Building in Phnom Penh. And as a curator you say that you want art to go beyond the gallery walls and make it more accessible for no-gallery walkers. You play with the concept of space and the functionality of the everyday objects and communal spaces. In this case, what would be the reason for exhibiting this particular, accessible space of sala samnak inside of an art gallery?**

My practice is a combination of two factors. On the one hand there is this interest in reaching out to the public and to the audience as much as possible, involving and engaging with communal and public spaces. On the other hand, most of my own art work has been presented inside of the gallery settings, despite that the work itself tends to touch on communal projects and projects that engage participants. For this particular sala samnak I'm interested in the idea of a communal space for anonymous people, visitors, and passersby as much as the villages.

When it comes to presenting it in the gallery, in the case of MIRAGE Contemporary Art Space, it has a corner with two glass windows and it is very visible directly from the street. I was thinking of how to maximise the visibility of the artwork. My work itself is a skeletal installation of neon light structure of one design of sala samnak. The installation itself will be placed at the corner of the gallery facing the street. In effect, the audience

# INTERVIEW

can see the work on both sides: from inside the gallery and they can walk around the corner of the gallery from outside and experience 180° of the work. I like this playfulness of how you can use the space from inside and outside of the gallery to enrich the experience for the audience.

**_ Certainly, the exhibition "Sala Samnak" ponders about the accessibility concept. This is a fragile installation and represents this dichotomy of space which is accessible and visible, but yet it is not, as it's a light installation hung in the space without a physical access to it.**

My initial idea was to create something in real size, or at least close to the real size of the structure, where people could walk in. But I couldn't do it in the gallery, because of the space limitation. So I then adjusted it, scaled it down, but I had to come up with another strategy to not lose on the impact.

You pointed out the tension between accessibility, but also in-accessibility and limitation. This is a practical condition of the space. Therefore, I had to think how I can use it and find my strategy to deal with this tension. Finally, I decided that the structure is suspended in mid-air, not touching the ground. That means that it appears as if it was floating, like it wasn't quite real, especially when you see the presence of this luminous blue structure. I like that quality of the light.

**_ What is unique for you to work with light and why did you opted to use it for this installation? What did the process look like?**

I have worked with light before. I have used light as a medium in my work, but this is the first time that I work with neon light, which is a very, very delicate and fragile material. I have learned a lot during this process. I am very grateful to have two colleagues joining me as a team to help me in digital rendering of the design and production and technical solution of the installation itself. It's been very challenging, as it's a new material for me.

I am very interested in the quality of this light. When the electricity is off it's just a white tube, it's nothing substantial. But when the electricity is on, this luminous lighting radiates and produces a magical quality to it. I like that. And I like the feeling when I see this kind of light, it is very mesmerizing. This quality of magic and mesmerizing makes me think about and connect it to the structure of sala samnak and its mixed relevance today: in certain places it is abandoned, in some others it is actively used, there are some new one being built.

I want to connect its precarious condition to the idea when the audience encounters the work that it creates this unearthly experience, sort of dream-like quality, that these images only exist in the imagination. And because this light is half-material. It's a tube, but the light itself you cannot touch. I like this kind of quality from the material itself, which pairs with the notion of the precarious condition of sala samnak. I forgot to mention that sala samnak has an ancient name *agni gRha*, *agni* being fire and *gRha* house, which translated means the house of fire. Perhaps in the old days there was a ritual of giving fire to the divine in this house. Ultimately, I am interested in how we can reuse and rethink light and fire to connect it with its old meaning, and how I can use new material to present this very particular experience for the audience.

>

# INTERVIEW

**_ In that way, your installation is sort of a documentation of the evolution of light and function of the sala samnak. And yet now we have another evolution of spaces, which with the pandemic are diluting and changing their definition. Public and communal spaces are suddenly becoming restricted and inaccessible, limited. What would be your take on social distancing and changes in the accessibility of spaces which the pandemic brought upon us?**

Indeed, it's another evolution and it changed how we interact and socialize with public spaces. That brings also a question of intimacy. We are less intimate, less close, social relations are being stretched. Having said that, Cambodia has been lucky that we haven't been hit hard in comparison to many other countries in the world.

As an artist, I want to bring and facilitate that intimacy and I hope that this work, and the quality of the light itself allows the audience to have a new form of an interaction and experience with an artwork inside and outside of the gallery. It refers to the qualities of the neon-light. On the one hand it's graspable, touchable, on the other hand it's not. It's sort of a paradox: you cannot touch light, you can touch the tube itself, but you cannot really touch light. And I hope that this offers some imagination and thinking and allows us to contemplate and re-think.

# CATALOGUE



វុធ លីណូ
សាលាសំណាក់, ២០២០
ស្នាដៃបង្គុំធ្វើពីអំពូលនីអុង
៣០០ x ២០០ x ២២៥សម

Vuth Lyno
Sala Samnak, 2020
Neon light installation
300 x 200 x 225 cm

# CATALOGUE



វុធ លីណូ
សាលាសំណាក់ ព្រែកដំបូក, ២០២១
គូរដោយ ថន សុខ
ពណ៌អាគ្រីលិក លើកំណាត់, ៥០ x ៣៧.៥ សម

Vuth Lyno
Sala Samnak Prek Dambauk, 2021
Painted by Than Sok
Acrylic on Canvas, 50 x 37.5 cm



វុធ លីណូ
សាលាសំណាក់ ១, ២០២១
គូរដោយ ថន សុខ
ពណ៌អាគ្រីលិក លើកំណាត់, ៥០ x ៣៧.៥ សម

Vuth Lyno
Sala Samnak 1, 2021
Painted by Than Sok
Acrylic on Canvas, 50 x 37.5 cm



វុធ លីណូ
សាលាសំណាក់ ២, ២០២១
គូរដោយ ថន សុខ
ពណ៌អាគ្រីលិក លើកំណាត់, ៥០ x ៣៧.៥ សម

Vuth Lyno
Sala Samnak 2, 2021
Painted by Than Sok
Acrylic on Canvas, 50 x 37.5 cm

# CATALOGUE



វុធ លីណូ
សាលាសំណាក់ ៣, ២០២១
គូរដោយ ថន សុខ
ពណ៌អាគ្រីលិក លើកំណាត់, ៥០ x ៣៧.៥ សម

Vuth Lyno
Sala Samnak 3, 2021
Painted by Than Sok
Acrylic on Canvas, 50 x 37.5 cm



វុធ លីណូ
សាលាសំណាក់ ៤, ២០២១
គូរដោយ ថន សុខ
ពណ៌អាគ្រីលិក លើកំណាត់, ៥០ x ៣៧.៥ សម

Vuth Lyno
Sala Samnak 4, 2021
Painted by Than Sok
Acrylic on Canvas, 50 x 37.5 cm



វុធ លីណូ
សាលាសំណាក់ ថ្ងៃស្អែក, ២០២១
គូរដោយ ថន សុខ
ពណ៌អាគ្រីលិក លើកំណាត់, ៥០ x ៣៧.៥ សម

Vuth Lyno
Sala Samnak Tomorrow, 2021
Painted by Than Sok
Acrylic on Canvas, 50 x 37.5 cm

# PROGRAMME

## សាលាសំណាក់
## SALA SAMNAK
ពិព័រណ៌ | On Show: November 21, 2020 – March 1, 2021

—

## សម្ពោធ
## OPENING NIGHT
Friday November 20, 2020 at 6:00pm
Catering Partners: Celliers d'Asie and JARRED

—

## ជួបជាមួយសិល្បករ: វុធ លីណូ
## ARTIST TALK WITH VUTH LYNO
Saturday February 13, 2021 at 4:00 pm
Khmer with English language support
Free of charge
Part of the Kraum Chat Makers Market Programme (more info below)

—

## ផ្សារក្រោមឆ័ត្រ
## KRAUM CHAT MAKERS MARKET
Saturday + Sunday February 13 + 14, 2021 from 12:00 until 8:00pm
A new makers market in Siem Reap to connect the creative community:
Design, art, music, workshops, food, drinks and more
Find out more on Facebook & Instagram: @kraumchat

—

For updated events, follow us on Facebook & Instagram!
@miragesiemreap

# VENUE

## About MIRAGE Contemporary Art Space

MIRAGE Contemporary Art Space is led by a collective of Cambodian and international artists and creatives. We focus on presenting and empowering Khmer artists and to make their art accessible to both a local and international audience. Since 2018, we have curated, designed and hosted over a dozen exhibitions and art events showcasing Khmer artists. Our approach is community driven, and each exhibition is accompanied by educational events such as art talks and workshops. Besides hosting changing art exhibitions at our gallery in the city center of Siem Reap, we regularly work with like-minded organisations and individuals in co-hosting cultural and artistic events. These include pop-up design markets, short film nights, skateboarding contests and school trips to visit art exhibitions. We also collaborate with NGO’s, schools and other youth organisations, and aim at making the world of art accessible to the younger generations. We understand our art gallery as a space for Cambodian artists to express themselves freely and connect with a wide audience and artists from all over the world.

Our mission is that of re-discovery, presentation and preservation of Khmer art and culture, operating in a multicultural and inclusive manner, promoting artists and performers that fully reflect the cultural diversity of Cambodia. We believe that artists and creative professionals need to experiment, bounce ideas off one another and work in a collaborative manner to create their next master work. MIRAGE offers this kind of space to local, regional and international arts professionals and emerging artists to exhibit, perform, meet, share, influence, collaborate and amalgamate ideas and inspirations. At MIRAGE we seek to enhance the cultural landscape of Siem Reap by bringing artists from other Cambodian cities and from neighboring ASEAN countries, reaching new audiences, and generating dialogue with and around contemporary arts.

MIRAGE Contemporary Art space operates on a not-for-profit basis. 100% of our profit from sale commissions goes into the realisation of future art projects. Your support helps us to promote and support the emerging Cambodian art scene.

MIRAGE

Contemporary Art Space
Oknha Oum Chhay Street / Street 03
Siem Reap, Cambodia

Wednesday – Saturday, 4:00 pm – 8:00 pm

miragesiemreap
art@mirage-collective.com
www.mirage-collective.com